វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ANZ Royal

# សន្ទេបចក្ខុវិស័យប្រទេសកម្ពុជា

ឆ្នាំ២០១៤ លេខ ០៤

## អាទិភាពគោលនយោបាយបានលើកឡើងក្នុង សន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១៤

### ១. បន្តការអភិវឌ្ឍសម្រាប់គ្រប់គ្នា ដោយផ្តោតលើការគ្រប់គ្រងដីធ្លីប្រកបដោយសមធម៌ និងការលើកកម្ពស់កម្រិតជីវភាព

- បន្តជំរុញការកែលំអការគ្រប់គ្រងដី ដោយធ្វើការចុះបញ្ជីដីធ្លីនៅតាមតំបន់មានអសន្តិសុខក្នុងការកាន់កាប់ដី និងពង្រឹងការត្រួតពិនិត្យដីសម្បទានសេដ្ឋកិច្ច
- កំណត់គោលនយោបាយប្រាក់បៀវត្សរ៍ទូទាំងប្រទេសឲ្យមានយុត្តិធម៌ និងការថ្លឹងថ្លែងល្អរវាង តម្រូវការឲ្យកម្ពុជា មានលក្ខណៈប្រកួតប្រជែងផ្នែកសេដ្ឋកិច្ច និងតម្រូវការឲ្យពលករមានកម្រិតជីវភាពសមរម្យ
- បង្កើនលទ្ធភាពទទួលបានសេវាសង្គម ដើម្បីជួយដល់គ្រួសារក្រីក្រ។

### ២. កំណត់យុទ្ធសាស្ត្រ និងពង្រឹងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច ដើម្បីគ្រប់គ្រងដំណាក់កាលបន្ទាប់នៃការរីកលូតលាស់

- ពង្រឹងយន្តការត្រួតពិនិត្យផ្នែកម៉ាក្រូហិរញ្ញវត្ថុ ដើម្បីគ្រប់គ្រងលើហានិភ័យផ្សេងៗដែលជាប់ទាក់ទងនឹងកំណើនយ៉ាងលឿននៃការផ្តល់ឥណទាន
- ផ្តល់ការលើកទឹកចិត្តផ្នែកសារពើពន្ធ ដើម្បីឲ្យអាជីវកម្មនានាចូលរួមក្នុងសេដ្ឋកិច្ចផ្លូវការ
- បង្កើនការប្រមូលប្រាក់ចំណូលសាធារណៈ និងកសាងយុទ្ធសាស្ត្រជំរុញការប្រើប្រាស់ថវិកាសម្រាប់កំណែទម្រង់សង្គមឲ្យមានប្រសិទ្ធភាព និងតម្លាភាព។

### ៣. លុបបំបាត់ឧបសគ្គរបវន្តដែលរារាំងការសម្រេចបាននូវគោលដៅនាំចេញ ជាពិសេស ផែនការនាំចេញអង្ករឲ្យបាន ១ លានតោនក្នុងមួយឆ្នាំ នៅត្រឹមឆ្នាំ២០១៥

- បង្កើនសមត្ថភាពហេដ្ឋារចនាសម្ព័ន្ធរបវន្តរបស់កម្ពុជា ដើម្បីផលិត និងដឹកជញ្ជូនអង្ករឲ្យបានច្រើនគ្រប់គ្រាន់
- កាត់បន្ថយតម្លៃថាមពលអគ្គិសនី តាមការបង្កើនការផ្គត់ផ្គង់ថាមពលវារីអគ្គិសនី ដោយរក្សាបាននូវចីរភាពល្អផ្នែកបរិស្ថាន និងសង្គម
- ពង្រីកបណ្តាញអគ្គិសនីនៅទូទាំងប្រទេស ដោយសម្រេចឲ្យបាននូវគោលដៅនៃការពង្រីកបណ្តាញខ្សែកាបួបញ្ជូនអគ្គិសនី។

### ៤. លើកកម្ពស់វិធីសាស្ត្រផ្តោតលើគុណភាពក្នុងវិស័យអប់រំ តាំងពីកម្រិតបឋមសិក្សា ដល់ឧត្តមសិក្សា

- ផ្តោតការយកចិត្តទុកដាក់លើអត្រាបញ្ចប់ការសិក្សា ជាជាងលើ អត្រាចុះឈ្មោះចូលរៀន ជាពិសេស នៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា
- កសាងសមត្ថភាពរបស់គ្រូបង្រៀន និងអ្នកបណ្តុះបណ្តាលគ្រូបង្រៀន ដោយផ្តល់ការបណ្តុះបណ្តាលសមស្រប និងតម្លើងប្រាក់បៀវត្សរ៍របស់គ្រូបង្រៀននៅគ្រប់កម្រិតទាំងអស់
- រៀបចំបទបញ្ញត្តិឲ្យបានកាន់តែប្រសើរសម្រាប់គ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា ដើម្បីលើកកម្ពស់ស្តង់ដារបង្រៀន និងផ្តល់ឲ្យនិស្សិតនូវសមត្ថភាពជំនាញមានស្តង់ដារច្បាស់លាស់។

### ៥. ធានាឲ្យ ប្រព័ន្ធអប់រំនៅកម្ពុជាអាចផ្តល់នូវ ជំនាញដែលនិយោជកត្រូវការនាពេលបច្ចុប្បន្ន និងទៅអនាគត

- លើកកម្ពស់ ការអប់រំនិងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ដើម្បីដោះស្រាយកង្វះខាតការផ្គត់ផ្គង់ពលករពាក់កណ្តាលជំនាញ និងជួយជំរុញដល់វិស័យកម្មន្តសាល និងសេវាកម្ម
- បង្កើនលំហូរព័ត៌មានស្តីពីទីផ្សារការងារ ដើម្បីឲ្យតម្រូវការរបស់និយោជក មានដាក់បញ្ចូលនៅក្នុងកម្មវិធីសិក្សា ហើយសិស្សនិងនិស្សិតក៏ទទួលបានការណែនាំសមស្របអំពីគម្រោងបណ្តុះបណ្តាល និងឱកាសការងារផ្សេងៗ
- ដាក់បញ្ចូលមុខវិជ្ជាផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) ឲ្យបានពីដើមដៃ ដើម្បីឲ្យសិស្សអាចត្រៀមខ្លួនបានល្អសម្រាប់មុខរបរទាមទារជំនាញខ្ពស់ ដែលនឹងត្រូវជំរុញដំណាក់កាលបន្ទាប់នៃការអភិវឌ្ឍ។

---

អាទិភាពផ្នែកគោលនយោបាយទាំងនេះ ផ្អែកលើ បទបង្ហាញ និងវគ្គសំណួរចម្លើយនានា នៃសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១៤។

លទ្ធផលនៃសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០១៤
ក្នុងកិច្ចសហការជាដៃគូរវាងវិទ្យាស្ថាន CDRI និង ធនាគារ ANZ Royal

### ៦. ពង្រីកការអប់រំមានគុណភាពល្អ ទៅដល់គ្រប់ស្រទាប់សង្គម ជាពិសេស ប្រជាជននៅតាមតំបន់ជនបទ

- កាត់បន្ថយការបែងចែករវាងតំបន់ជនបទ និងទីក្រុង ក្នុងការផ្តល់សេវាអប់រំ តាមការកសាងកន្លែងសិក្សាអប់រំនៅតាមតំបន់ជាយ, ផ្តល់ការលើកទឹកចិត្តដល់គ្រូបង្រៀន និងបង្កើនលទ្ធភាពបានប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន (ICT) និងសម្ភារៈបង្រៀនផ្សេងៗទៀត
- បណ្តុះវប្បធម៌អប់រំក្នុងចំណោមគ្រួសារក្រីក្រនៅជនបទ ដោយជួយឲ្យពួកគេបានចូលពាក់ព័ន្ធនឹងការបង្រៀន ដោយបើកដំណើរការមត្តេយ្យសាលា និងដោយធានាឲ្យសិស្សមានកម្រិតអាហារូបត្ថម្ភគ្រប់គ្រាន់
- ផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ ដើម្បីឲ្យបានចូលសិក្សាក្នុងគ្រឹះស្ថានឧត្តមសិក្សា ហើយចូលរួមចំណែកបង្កើនចំនួនពលករមានជំនាញ និងជួយជំរុញការអភិវឌ្ឍសម្រាប់គ្រប់គ្នា។

### ៧. ធ្វើឱ្យប្រសើរឡើងទៀតនូវ ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ដើម្បីទាញយកប្រយោជន៍ឲ្យបានច្រើនបំផុតពីសមាជិកភាពក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន តាមរយៈពាណិជ្ជកម្មឆ្លងកាត់, កំណើនការនាំចេញ, និងការធ្វើសមាហរណកម្មចូលទៅក្នុងបណ្តាញផលិតកម្មក្នុងតំបន់

- បន្តធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនរូបវន្ត ដើម្បីបង្កើនការតភ្ជាប់ជាមួយចំណុចប្រសព្វក្នុងតំបន់ ពោលគឺ ក្រុងបាងកក និង ក្រុងហូជីមិញ
- ជំរុញការប្រកួតប្រជែងក្នុងសេវាភស្តុភារ តាមការបង្កើនស្តង់ដារ និងការធ្វើសមាហរណកម្មបណ្តាញភស្តុភារ នៅតាមតំបន់ដាច់ស្រយាល និងឆ្លងកាត់ព្រំដែន
- កសាងសមត្ថភាពមន្ត្រីគយ ដើម្បីអនុវត្តនីតិវិធីឲ្យមានតម្លាភាព ភាពប្រាកដប្រជា និងប្រសិទ្ធភាព។

### ៨. ពង្រឹងសហគ្រាសខ្នាតតូចនិងមធ្យម (SMEs) ដើម្បីរក្សាសមត្ថភាពប្រកួតប្រជែងនៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន និងធ្វើពិពិធកម្មសេដ្ឋកិច្ច

- បង្កើនផលិតភាព SMEs ដោយរៀបចំរបៀបរបបធ្វើអាជីវកម្មឲ្យមានលក្ខណៈផ្លូវការ ដូចជា ការកំណត់ស្តង់ដារធ្វើរបាយការណ៍ហិរញ្ញវត្ថុ និងតារាងតុល្យការ ដើម្បីអាចធ្វើសវនកម្មបានត្រឹមត្រូវ ហើយលើកទឹកចិត្តធនាគារឲ្យបង្កើនការផ្តល់ប្រាក់កម្ចី និងទាក់ទាញថែមទៀតនូវវិនិយោគផ្ទាល់ពីបរទេស
- ពង្រីកសេវាជួយគាំទ្រដល់ SMEs ដើម្បីឲ្យរីកលូតលាស់ចូលទៅក្នុងទីផ្សារថ្មីៗ តាមការបង្កើនទុនផ្នែកបច្ចេកទេស និងការគ្រប់គ្រង និងការផ្តល់ព័ត៌មានទីផ្សារថ្មីទាន់ពេលដល់ពួកគេ
- ត្រួតពិនិត្យកំណើនរំពឹងទុកនៃវិនិយោគផ្ទាល់ពីបរទេសទៅក្នុង SMEs ដោយត្រូវក្តាប់ឲ្យបានអំពីកាតព្វកិច្ច និងបំណុលផ្សេងៗ និងចាត់វិធានការដោះស្រាយក្នុងករណីមានការប៉ះទង្គិចពីខាងក្រៅ។

### ៩. លុបបំបាត់វិធានការមិនមែនពន្ធគយ (NTMs) ដែលអាចបន្ទុចបង្អាក់អ្នកនាំចេញក្នុងការប្រើប្រាស់ ក្របខ័ណ្ឌសហគមន៍សេដ្ឋកិច្ចអាស៊ាន ដើម្បីធ្វើពាណិជ្ជកម្ម

- ផ្តល់ព័ត៌មានដល់មជ្ឈដ្ឋានឧស្សាហកម្មអំពី អត្ថប្រយោជន៍នៃការប្រើប្រាស់ក្របខ័ណ្ឌសហគមន៍សេដ្ឋកិច្ចអាស៊ានសម្រាប់ធ្វើពាណិជ្ជកម្ម និងនីតិវិធីដើម្បីប្រើប្រាស់វា
- ធ្វើឲ្យសាមញ្ញនូវនីតិវិធីសម្រាប់ឲ្យពាណិជ្ជករប្រើប្រាស់ក្របខ័ណ្ឌសហគមន៍សេដ្ឋកិច្ចអាស៊ាន និង លុបចោលការតម្រូវឲ្យមានវិញ្ញាបនបត្រនាំចេញ
- ជំរុញឱ្យប្រទេសផ្សេងទៀតក្នុងអាស៊ាន តម្រឹមនូវនីតិវិធីប្រើប្រាស់ក្របខ័ណ្ឌសហគមន៍សេដ្ឋកិច្ចអាស៊ាន និងធ្វើការលុបបំបាត់ NTMs ក្នុងទូទាំងតំបន់។

### ១០. ចូលរួមក្នុងកំណែទម្រង់រដ្ឋបាលស៊ីវិល ដើម្បីបង្កើនសមត្ថភាពស្ថាប័នក្នុងការអនុវត្តរបបនីតិរដ្ឋឲ្យមានសមធម៌ និងតម្លាភាព

- ពង្រឹងស្ថាប័នសំខាន់ៗ ដូចជាប្រព័ន្ធតុលាការ ដើម្បីពង្រឹងការអនុវត្តកិច្ចសន្យាឲ្យបានប្រកបដោយសមធម៌ និងមានតម្លាភាព
- បង្កើនការសម្របសម្រួល និងសហប្រតិបត្តិការរវាងស្ថាប័នរដ្ឋនានា ដើម្បីអាចឆ្លើយតបបានឆាប់រហ័ស និងប្រកបដោយប្រសិទ្ធភាព ទៅនឹងការផ្លាស់ប្តូរផ្សេងៗក្នុងលក្ខខណ្ឌសេដ្ឋកិច្ច
- បង្កើនសមត្ថភាពមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ក្នុងការអនុវត្តរបបនីតិរដ្ឋ តាមការបណ្តុះបណ្តាល និងការផ្តល់បៀវត្សរ៍ឲ្យបានគ្រប់គ្រាន់។

*ទស្សនៈទាំងឡាយនៅក្នុងឯកសារនេះ គឺជាគំនិតផ្ទាល់របស់អ្នកនិពន្ធ និងមិនមែនជាទស្សនៈរបស់វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា និង ធនាគារអេអិនហ្សិតរ៉ូយ៉ាល់ ទេ។*

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ/CDRI)**

☞ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក ✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា

☎ (៨៥៥ ២៣) ៨៨១ ៣៨៤, ៨៨១ ៧០១, ៨៨១ ៩១៦, ៨៨៣ ៦០៣ 🖷 (៨៥៥ ២៣) ៨៨០ ៧៣៤

e-mail: cdri@cdri.org.kh, website: www.cdri.org.kh